# លំហូរនៃការទទួលវ៉ាក់សាំងការពារជម្ងឺកូវីដ ១៩

វ៉ាក់សាំងការពារជម្ងឺកូវីដ១៩ អាចចាក់បានដោយឥតគិតថ្លៃ។
ជនបរទេសដែលមិនមានសំបុត្រប្រជាជន ដូចជាអ្នកដែលត្រូវបានដោះលែងជាបណ្ដោះអាសន្នជាដើម ក៏អាចទទួលការចាក់វ៉ាក់សាំងបានដែរ។

1. ទទួលបាន “ប័ណ្ណចាក់វ៉ាក់សាំង (ប័ណ្ណគូប៉ុង)” និង “សេចក្ដីជូនដំណឹងអំពីការចាក់វ៉ាក់សាំងការពារជម្ងឺកូវីដ១៩” ពីអភិបាល

   អំឡុងពេលនៃការទទួលប័ណ្ណចាក់វ៉ាក់សាំង ខុសគ្នាទៅតាមតំបន់ និងអាយុ។
   សម្រាប់ជនបរទេសដែលមិនមានចុះបញ្ជីប្រជាជននៅសាលាក្រុងទេ សូមទៅពិភាក្សាជាមួយសាលាក្រុងនៅតំបន់ដែលខ្លួនស្នាក់នៅ ដោយបង្ហាញឯកសារដែលអាចដឹងពីអាសយដ្ឋានរបស់អ្នក។

   គំរូនៃប័ណ្ណចាក់វ៉ាក់សាំង (នេះជាគំរូរបស់ទីក្រុងកូបេ។ ការរចនារូបភាព អាចនឹងខុសគ្នាទៅតាមតំបន់នីមួយៗ)




原稿作成・翻訳：NPO 法人 多言語センターFACIL
https://tcc117.jp/facil/
※本活動は一般財団法人寺山財団からの寄付を受けて実施しています。

2. ធ្វើការកក់ទុកជាមុនសម្រាប់ការចាក់លើកទី១
វ៉ាក់សាំង ត្រូវចាក់ ២ដង។ ដំបូង ត្រូវកក់ទុកជាមុនសម្រាប់ការចាក់លើកទី ១។

<វិធីកក់ទុកជាមុន>

- ករណីទទួលការចាក់វ៉ាក់សាំងនៅទីតាំងដែលរៀបចំដោយអភិបាល
អាចកក់ទុកជាមុនតាមរយៈគេហទំព័ររបស់អភិបាល ឬ
ទូរស័ព្ទទៅកាន់កន្លែងទទួលរបស់អភិបាលដើម្បីធ្វើការកក់ទុកជាមុន។
នៅលើសេចក្តីជូនដំណឹងអំពីការចាក់វ៉ាក់សាំង មានសរសេរអំពីគេហព័រ ឬ QR កូដ
សម្រាប់ការកក់ទុកជាមុន និងលេខទូរស័ព្ទកន្លែងទទួលផងដែរ។

- ករណីទទួលការចាក់វ៉ាក់សាំងនៅតាមស្ថាប័នសុខាភិបាល (មន្ទីរពេទ្យដែលតែងតែទៅ ជាដើម)
វិធីកក់ទុកជាមុន អាចនឹងខុសគ្នាទៅតាមអភិបាលនីមួយៗ ហេតុនេះ សូមពិនិត្យមើលសេចក្តីជូនដំណឹង
ឬគេហទំព័ររបស់អភិបាល។
មានករណីធ្វើការកក់ទុកជាមុនដោយផ្ទាល់ទៅកាន់ស្ថាប័នសុខាភិបាល (តាមរយៈគេហទំព័រ
ឬលេខទូរស័ព្ទ) និង
ករណីធ្វើការកក់ទុកជាមុនតាមរយៈគេហទំព័រ ឬ ទូរស័ព្ទទៅកាន់កន្លែងទទួលរបស់អភិបាល។

ស្ថាប័នសុខាភិបាលដែលអាចទទួលការចាក់វ៉ាក់សាំង អាចរកបានតាមរយៈគេហទំព័រខាងក្រោម។
ភាសាជប៉ុន ៖ https://v-sys.mhlw.go.jp/search/
ភាសាអង់គ្លេស ៖ https://v-sys.mhlw.go.jp/en/search

ក្រៅពីនេះ កន្លែងធ្វើការ និងសាកលវិទ្យាល័យ ក៏អាចក្លាយជាកន្លែងទទួលវ៉ាក់សាំងផងដែរ។

※សូមប្រយ័ត្នកុំធ្វើការកក់ទុកជាមុនលើសពី ១កន្លែង
※វិធី និងលំដាប់លំដោយនៃការកក់ទុកជាមុន អាចមានការប្រែប្រួលនៅពេលក្រោយ។

3. ទទួលវ៉ាក់សាំងលើកទី១
សូមភ្ជាប់មកជាមួយ ៖ ប័ណ្ណចាក់វ៉ាក់សាំង ឯកសារបញ្ជាក់ពីអត្តសញ្ញាណខ្លួន (កាតស្នាក់នៅ លិខិតឆ្លងដែន
កាតម៉ាយណាំប័រ ជាដើម)
សំបុត្រកក់ទុកជាមុន (មកជាមួយនឹងប័ណ្ណចាក់វ៉ាក់សាំង ហេតុនេះសូមសរសេរទុកជាមុន។ គំរូ
មានច្រើនភាសា សូមពិនិត្យមើលគេហទំព័រខាងក្រោម។)
https://www.mhlw.go.jp/stf/seisakunitsuite/bunya/vaccine_tagengo.html

4. ធ្វើការកក់ទុកជាមុនសម្រាប់ការចាក់លើកទី២

5. ទទួលការចាក់វ៉ាក់សាំងលើកទី ២

ចំណុចប្រុងប្រយ័ត្នក្រោយពេលចាក់វ៉ាក់សាំង
ក្រោយពេលចាក់វ៉ាក់សាំងភ្លាម សូមរង់ចាំនៅកន្លែងចាក់រយៈពេល ១៥ ទៅ ៣០នាទី។

ក្រោយពេលចាក់វ៉ាក់សាំង អាចមានស្ថានភាពមិនស្រួលខ្លួន។
ប្រសិនបើអការៈធ្ងន់ធ្ងរ ហើយប៉ុន្មានថ្ងៃក្រោយមិនមានសភាពធូរស្រាលទេ
សូមធ្វើការពិគ្រោះជាមួយស្ថាប័នសុខាភិបាល។

ក្រោយពេលចាក់វ៉ាក់សាំងរួចក៏ដោយ សូមបន្តវិធានការការពារដោយការពាក់ម៉ាសជាដើម។

原稿作成・翻訳：NPO 法人 多言語センターFACIL
https://tcc117.jp/facil/
※本活動は一般財団法人寺山財団からの寄付を受けて実施しています。

ទំនាក់ទំនងសួរពត៌មាន
អំពីពត៌មានទូទៅទាក់ទងនឹងវ៉ាក់សាំង ៖
　កន្លែងផ្តល់ពត៌មានតាមទូរស័ព្ទទាក់ទងនឹងវ៉ាក់សាំងកូវីដ១៩ របស់ក្រសួងការងារ
　០១២០-៧៦១៧៧០ (ឥតគិតថ្លៃ  និងទទួលទាំងថ្ងៃសៅរ៍ អាទិត្យ និងបុណ្យ)
　ភាសាជប៉ុន អង់គ្លេស ចិន កូរ៉េ ប៉ទុយហ្គាល និងអេស្ប៉ាញ ៖ ៩:០០-២១:០០
　ភាសាថៃ ៖ ៩:០០-១៨:០០
　ភាសាវៀតណាម ៖ ១០:០០-១៩:០០
　※ដំបូង នឹងមានការនិយាយជាភាសាជប៉ុន។ សូមនិយាយថា “សឺយ៉ាគី ស្ដិ ហូស៊ី”។

ទាក់ទងនឹងការកក់ទុកជាមុន ៖ សូមពិភាក្សាជាមួយសាលាក្រុងដែលនៅតំបន់ដែលអ្នករស់នៅ។

ប្រភព និងឯកសារយោង

「ワクチン 接種までの流れ 接種予約は」（NHK　新型コロナウイルス特設サイト）
https://www3.nhk.or.jp/news/special/coronavirus/vaccine/flow/

「コロナワクチンナビ」（厚生労働省）
https://v-sys.mhlw.go.jp/

「外国人住民向けにコロナワクチン情報発信。多言語コールセンターや 17 言語でのお知らせも」（Buzz Feed）
https://www.buzzfeed.com/jp/sumirekotomita/covid-vaccine-1

「接種券見本」（神戸市）
https://www.city.kobe.lg.jp/documents/42676/t-1.pdf

原稿作成・翻訳：NPO 法人 多言語センターFACIL
https://tcc117.jp/facil/
※本活動は一般財団法人寺山財団からの寄付を受けて実施しています。